**Mekong Watch**
3F Aoki Building 1-12-11 Taito
Taito-ku, Tokyo 110-0016 Japan
E-mail: info@mekongwatch.org
Website: http://www.mekongwatch.org

**3S Rivers Protection Network**
Okantuel Village
Sangkat Bueng Kanseng
Banlung, Ratanakiri, Cambodia
E-mail: info@3spn.org
Website: http://www.3spn.org

# សម្រង់ចំណុចសំខាន់ៗសម្រាប់សហគមន៍
# ការណែនាំសហគមន៍ទៅលើគោលការណ៍ណែនាំរបស់ចិន
# សម្រាប់ការការពារបរិស្ថាននៅក្នុងការវិនិយោគបរទេស និងសហប្រតិបត្តិការ

## សួស្តីបងប្អូនសហគមន៍ជាទីរាប់អាន !

អ្នកប្រហែលជាទទួលរងនូវផលប៉ះពាល់ពីគម្រោងអភិវឌ្ឍរបស់ចិន និង មានអារម្មណ៍ខកចិត្តដោយសារៈ

1) អ្នកបានសាកសួរព័ត៌មានពីក្រុមហ៊ុនចិនអំពីព័ត៌មានពីគម្រោងពួកគេ ប៉ុន្តែពួកគេមិនបានឆ្លើយតបដល់អ្នកវិញទេ
2) ក្រុមហ៊ុនចិនបានបំផ្លាញខ្ទមអ្នកតាដែលសហគមន៍របស់អ្នកគោរពប្រតិបត្តិ
3) កម្មកររបស់ក្រុមហ៊ុនចិនបានមកធ្វើការសិក្សាក្នុងសហគមន៍របស់អ្នកដោយមិនជូនដំណឹងអ្វីទាំងអស់
4) កម្មករចិនបានចូលមកដល់ការស្រាវជ្រាវនៅក្នុងសហគមន៍របស់អ្នក ដោយមិនមានសេចក្តីជូនដំណឹងជាមុន ហើយសូម្បីតែអាជ្ញាធរមូលដ្ឋានក៏មិនត្រូវបានគេជូនដំណឹងពីសកម្មភាពរបស់ពួកគេដែរ
5) ទឹកទន្លេបានប្រែមកជាកខ្វក់ដោយសារតែសកម្មភាពសាងសង់ ឬការអភិវឌ្ឍណាមួយ
6) មានទឹកជំនន់មិនបានគ្រោងទុក ឬ ការប្រែប្រួលនូវគុណភាពទឹកដែលអ្នកគិតថា អាចបង្កឡើងដោយសារគម្រោង
7) ក្រុមហ៊ុនចិនមិនបានចុះមកដល់សហគមន៍ ដើម្បីធ្វើការស្រាវជ្រាវទៅលើផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានដោយសារគម្រោងរបស់ពួកគេ
8) អ្នកបានឮថា អ្នកនឹងត្រូវផ្លាស់ទី(រើតាំងទីលំនៅថ្មី) ដោយសារតែគម្រោង ប៉ុន្តែអ្នកមិនដឹងថាពេលណា ឬ ត្រូវទៅកន្លែងណា ហើយពួកគេក៏មិនបានពិគ្រោះយោបល់ជាមួយអ្នក ឬផ្តល់ឱកាសឲ្យអ្នកបង្ហាញពីកង្វល់របស់ខ្លួនដែរ
9) កម្មករចិនមិនបានស្តាប់ពីកង្វល់របស់អ្នក ឬមិនអាចយល់ពីអ្វីដែលអ្នកបាននិយាយ ឬ ឆ្លើយតបនឹងសំណួររបស់អ្នកអំពីការការពារបរិស្ថាន។

នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៣ ដោយសារមានការដាក់សម្ពាធដោយពាក្យបណ្តឹង ឬលិខិតជាច្រើនមកពីទូទាំងពិភពលោកលើឥរិយាបថ ឬការអនុវត្តរបស់ក្រុមហ៊ុនចិន ដែលមិនបានយកចិត្តទុកដាក់គោរពសហគមន៍មូលដ្ឋាន និងបរិស្ថានក្នុងតំបន់ធ្វើឲ្យក្រសួងពាណិជ្ជកម្ម និងក្រសួងបរិស្ថានរបស់ចិនរៀបចំ និងផ្សព្វផ្សាយគោលការណ៍ណែនាំ សំរាប់ការការពារបរិស្ថាននៅក្នុងសហប្រតិបត្តិការ និងការវិនិយោគបរទេស "**គោលការណ៍ណែនាំ**" ដើម្បីតម្រូវឲ្យសហគ្រាស (**ក្រុមហ៊ុន**) នៅក្នុងប្រទេសចិនឲ្យផ្តោតយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការការពារបរិស្ថានចំពោះការវិនិយោគ និង កិច្ចសហប្រតិបត្តិការបរទេសដោយណែនាំឲ្យពួកគេទទួលខុសត្រូវខ្ពស់លើការងារការពារបរិស្ថាន និង

លើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងកិច្ចសហប្រតិបត្តិការបរទេស"។

តែជាអកុសល គោលការណ៍ណែនាំនេះគឺនៅតែទន់ខ្សោយ និងខ្វះខាត។ ***ឧទាហរណ៍ ពួកគេ គឺត្រូវអនុវត្ត គោលការណ៍ណែនាំដោយស្ម័គ្រចិត្ត។*** បើទោះជាក្រុមហ៊ុនចិនមិនបានអនុវត្តតាមគោការណ៍ណែនាំនេះក៏ដោយ ក៏ពួកគេនឹងមិនប្រឈមមុខចំពោះផ្លូវច្បាប់ណាមួយឡើយ។ វាក៏នៅមិនមានភាពច្បាស់លាស់ អំពីទីកន្លែងដែល អ្នកអាចផ្ញើរពាក្យបណ្តឹង ឬ លិខិតជូនដំណឹងនៅពេលដែលអ្នកគិតថា ក្រុមហ៊ុនចិនមិនបានអនុវត្តតាមគោលការណ៍ណែនាំនេះ ចាំបាច់ត្រូវការកែសម្រួលបន្ថែមទៀត។ ប៉ុន្តែដើម្បីធ្វើអោយគោលការណ៍ណែនាំនេះកាន់តែប្រសើរឡើង នោះពួកយើងគួរតែព្យាយាមប្រើប្រាស់វាជាមុនសិន បន្ទាប់មកយើងអាចបង្ហាញដល់អាជ្ញាធរចិនអំពីអ្វីដែលត្រូវការកែសម្រួលបន្ថែមដើម្បីឲ្យគោលការណ៍ណែនាំកាន់តែមានប្រសិទ្ធិភាព ឬល្អជាងមុន។

គោលការណ៍ណែនាំនេះ គឺមិនវែងទេ ហើយសហគមន៍អាចប្រើប្រាស់បានយ៉ាងងាយស្រួលដើម្បីគ្រប់គ្រងការអនុវត្តរបស់ក្រុមហ៊ុនចិន។ វាហាក់ដូចជាច្បាប់មួយដូច្នោះដែរ តែបើមានតែច្បាប់មួយនេះ គឺវាមិនគ្រប់គ្រាន់នោះទេ។ អ្នកគួរតែប្រើប្រាស់គោលការណ៍ណែនាំនេះ ដើម្បីផលប្រយោជន៍របស់អ្នក និងសហគមន៍របស់អ្នកទាំងមូល។

ទាំងនេះ គឺជាហេតុផលដែលយើងបានបកប្រែគោលការណ៍ណែនាំរបស់ប្រទេសចិនមកជាភាសាខ្មែរ និងដើម្បីជួយដល់សហគមន៍អ្នក ប្រសិនបើអ្នកប្រើប្រាស់គោលការណ៍ណែនាំនេះ។

**ខាងក្រោម គឺគំនិតមួយចំនួនដែលអ្នកត្រូវប្រើប្រាស់គោលការណ៍ណែនាំនេះ ៖**

1) នៅពេលក្រុមហ៊ុនចិនមិនបានផ្តល់ឲ្យអ្នកនូវព័ត៌មានគ្រប់គ្រាន់ពីគម្រោងរបស់ពួកគេ អ្នកអាចចង្អុលបង្ហាញថា៖ "ក្រុមហ៊ុន...បង្កើតយន្តការទំនាក់ទំនង និងកិច្ចពិភាក្សាសម្រាប់ការទទួលខុសត្រូវលើសង្គម និងបរិស្ថាន របស់សហគ្រាស ដោយផ្តួចផ្តើមក្នុងការពង្រឹងទំនាក់ទំនង និង ការប្រាស្រ័យទាក់ទងជាមួយសហគមន៍ និង អ្នកពាក់ព័ន្ធ" **(មាត្រា ២០)** ឬ " មុនពេលចាប់ផ្តើមដំណើរការគម្រោងសាងសង់ សហគ្រាសទាំងអស់ត្រូវបានជំរុញលើកទឹកចិត្តឲ្យពិនិត្យ និងវាយតម្លៃលើបរិស្ថាន សម្រាប់ការដ្ឋានសាងសង់ដែលបានស្នើឡើងនោះ។ ត្រូវស្វែងយល់អំពីស្ថានភាព និងប្រវត្តិទីតាំងរបស់គម្រោងនិងតំបន់ជុំវិញ និងបញ្ចូលលទ្ធផលនៃការពិនិត្យ និង វាយតម្លៃបរិស្ថាននោះទៅក្នុងរបាយការណ៍" **(មាត្រា១១)**

2) នៅពេលដែលកម្មករចិនបំផ្លាញខ្ទមអារក្សអ្នកតានៅក្នុងសហគមន៍របស់អ្នក អ្នកត្រូវចង្អុលបង្ហាញពួកគេថា ៖ "សហគ្រាស... គួរតែគោរពជំនឿសាសនា វប្បធម៌ប្រពៃណី និងទំនៀមទម្លាប់របស់ប្រជាជននៅក្នុងសហគមន៍នៃប្រទេសជាម្ចាស់ផ្ទះ" **(មាត្រា ៣)** ឬ "សហគ្រាសត្រូវបានលើកទឹកចិត្តយ៉ាងពេញលេញក្នុងការទទួលខុសត្រូវលើផលប៉ះពាល់ដែលកើតឡើងពីការអភិវឌ្ឍ និងការសាងសង់របស់ពួកគេ... ទៅលើសង្គម បរិស្ថាន ដូចជាបេតិកភ័ណ្ឌប្រវត្តិសាស្រ្ត វប្បធម៌ ទេសភាពធម្មជាតិ និងទំនៀមទំលាប់ប្រពៃណី ហើយចាត់វិធានការសមហេតុសមផល ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានតាមដែលអាចធ្វើបាន" **(មាត្រា៩)**

3) នៅពេលដែលកម្មករចិនចូលមកធ្វើការនៅក្នុងសហគមន៍របស់អ្នក ដោយមិនមានការជូនដំណឹងជាមុនទេនោះ អ្នកត្រូវចង្អុលបង្ហាញថា៖ "សហគ្រាស...គួរអនុវត្តការទទួលខុសត្រូវលើការការពារបរិស្ថាន ដោយបង្កើតរូបភាពដ៏ល្អសម្រាប់សហគ្រាសចិន" **(មាត្រា១)** ឬ "សហគ្រាស ត្រូវបានលើកទឹកចិត្តឲ្យចូលរួមយ៉ាងសកម្មនៅក្នុងការគាំទ្រដល់សកម្មភាពដែលជាផលប្រយោជន៍សាធារណៈ សម្រាប់សហគមន៍មូលដ្ឋានក្នុងការការពារបរិស្ថាន

ផ្សព្វផ្សាយជាសាធារណៈនូវគំនិតនៃការការពារបរិស្ថាន និង ការកសាងរូបភាពដ៏ល្អសម្រាប់សហគ្រាសមួយនៅក្នុងការគោរព ការ ការពារបរិស្ថាន" **(មាត្រា២១)**។ ហើយចំពោះគម្រោងដែលវិនិយោគលើការសាងសង់ ហើយប្រតិបត្តិការដោយសហគ្រាសទាំងនោះ គឺត្រូវសុំការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋានទាក់ទងទៅនឹងគោលការណ៍ការការពារបរិស្ថានអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ម្ចាស់ប្រទេស **(មាត្រា៥)**។

4) ពេលដែលក្រុមហ៊ុនចិនមិនបានធ្វើការស្រាវជ្រាវពីផលប៉ះពាល់អវិជ្ជមានរបស់គម្រោង អ្នកអាចចរចារ ឬ ចង្អុលបង្ហាញពួកគេនូវ **(មាត្រា៨ និង/ ឬមាត្រា ១១)**។
5) បើអ្នកមានអារម្មណ៍ថាក្រុមហ៊ុនចិនមិនបានអនុវត្តតាមច្បាប់កម្ពុជា ឬ បទប្បញ្ញត្តិ ឬ ស្តង់ដារដើម្បីការពារបរិស្ថាន អ្នកអាចចង្អុលបង្ហាញទៅពួកគេនូវ **(មាត្រា១០)**។
6) ប្រសិនបើក្រុមហ៊ុនចិនបានចាប់ផ្តើមការសាងសង់របស់ពួកគេមុនពេលពួកគេធ្វើការស្រាវជ្រាវលើស្ថានភាពបរិស្ថានក្នុងតំបន់ ឬពួកគេមិនបានផ្តល់នូវព័ត៌មានអំពីការតាមដាន ឬត្រួតពិនិត្យពីផលប៉ះពាល់បរិស្ថានណាមួយ អ្នកអាចចង្អុលបង្ហាញពួកគេនូវ **(មាត្រា១១)**។
7) ប្រសិនបើក្រុមហ៊ុនចិនបានចាក់ទឹកដែលមានជាតិពុលចូលទៅក្នុងទន្លេ ហើយវាប៉ះពាល់ដល់ត្រី រុក្ខជាតិ ដី និងមនុស្ស អ្នកអាចចង្អុលបង្ហាញពួកគេនូវ **(មាត្រា១៣)**។
8) ប្រសិនបើទឹកជំនន់ណាមួយបានកើតឡើងដោយមិនគ្រោងទុក ឬ កើតឡើងដោយការបើកបង្ហូរទឹកពីទំនប់វារីអគ្គិសនី ដែលបណ្តាលអោយខូចខាតដល់ផ្ទះ ទ្រព្យសម្បត្តិ ឬ ការចិញ្ចឹមជីវិតសហគមន៍ អ្នកអាចចង្អុលបង្ហាញពួកគេនូវ **(មាត្រា១៤)**។
9) ប្រសិនបើមានការបំពុលទឹកកើតឡើង ឬការផ្លាស់ប្តូរគុណភាពទឹកដែលគម្រាមកំហែង ឬ បំផ្លាញត្រី សត្វ-ពាហនៈ រុក្ខជាតិ ឬ បង្កអោយមានជំងឺសើរស្បែក និង ជំងឺផ្សេងទៀត ដែលអ្នកគិតថាបណ្តាលមកពីទំនប់វារីអគ្គិសនី នោះអ្នកអាចចង្អុលបង្ហាញពួកគេនូវ **(មាត្រា១៤)**។
10) ក្រុមហ៊ុនចិនត្រូវតែពិចារណាពីសត្វ និង ធនធានរុក្ខជាតិនៅក្នុងទន្លេ និង នៅជុំវិញទន្លេ។ ប្រសិនបើប្រភេទត្រីថយចុះ ឬ រុក្ខជាតិត្រូវបានបំផ្លាញដោយសារតែសកម្មភាពសាងសង់ ឬ ដោយសារគម្រោង អ្នកអាចចង្អុលបង្ហាញពួកគេនូវ **(មាត្រា១៥)**។
11) នៅពេលដែលទឹកទន្លេកខ្វក់ដោយសារតែសកម្មភាពសាងសង់ អ្នកអាចចង្អុលបង្ហាញពួកគេនូវ **(មាត្រា១៦)**។
12) ក្រុមហ៊ុនត្រូវតែផ្តល់ព័ត៌មានអំពីផលប៉ះពាល់បរិស្ថាន និង ផែនការគ្រប់គ្រងផលប៉ះពាល់ ទៅដល់សហគមន៍ដែលរងផលប៉ះពាល់មូលដ្ឋាន និង សាធារណៈ។ ព័ត៌មានទាំងនោះ គួរតែជាភាសាមូលដ្ឋាន ដែលសហគមន៍អាចយល់បាន។ ប្រសិនបើពួកគេមិនធ្វើដូចនេះ អ្នកអាចចង្អុលបង្ហាញពួកគេនូវ **(មាត្រា១៨)**។
13) ក្រុមហ៊ុន គួរតែអនុវត្តតាមច្បាប់ និង បទប្បញ្ញត្តិក្នុងស្រុកដែលនិយាយថាសហគមន៍ដែលរងផលប៉ះពាល់ និងសាធារណជនមានសិទ្ធិទទួលបានព័ត៌មាន និងពិគ្រោះយោបល់លើផ្នែកបរិស្ថាន ក្នុងការធ្វើសេចក្តីសម្រេចចិត្ត។ ប្រសិនបើពួកគេមិនផ្តល់នូវព័ត៌មាន ឬមិនបានប្រជុំដើម្បីស្តាប់ការព្រួយបារម្ភរបស់សហគមន៍ អ្នកអាចចង្អុលបង្ហាញពួកគេនូវ **(មាត្រា២០ និងមាត្រា១០)**។
14) ប្រសិនបើកម្មករចិនមិនអាចយល់សំណួររបស់អ្នក ឬ មិនយល់ពីមូលហេតុដែលនាំអ្នកមានការត្អូញត្អែរអំពីការការពារបរិស្ថានទេ សូមជូនដំណឹងមកដល់យើង។ យើងអាចជួយធ្វើការតវ៉ា ឬចរចារជាមួយក្រុមហ៊ុនចិន ឬរដ្ឋាភិបាលដែលពួកគេមិនបានបណ្តុះបណ្តាលកម្មកររបស់ពួកគេ។ សហគ្រាស ឬ ក្រុមហ៊ុនគួរបង្កើតប្រព័ន្ធបណ្តុះបណ្តាលពីការការពារបរិស្ថានដល់បុគ្គលិកអោយបានត្រឹមត្រូវ និងបណ្តុះបណ្តាលអោយចេះគោរព ឬ

ការពារបរិស្ថាន សុខភាព និងសុវត្ថិភាពការងារ... " (**មាត្រា៧**)។ ជាងនេះទៀត ក្រុមហ៊ុនក៏គួរតែមានបុគ្គលិក ដែលរក្សាទំនាក់ទំនងយ៉ាងជិតស្និត និងសកម្មជាមួយសហគមន៍លើបញ្ហាបរិស្ថាន (**មាត្រា២០**)។

ទាំងនេះ គ្រាន់តែជាឧទាហរណ៍ពីរ បី ប៉ុណ្ណោះ។ ចូរធ្វើការសិក្សាបន្ថែមទៅលើគោលការណ៍ណែនាំ ដោយយកចិត្តទុកដាក់ដោយខ្លួនឯងបន្ថែមទៀត។

សូមចងចាំថា គោលបំណងនៃមគ្គុទេសក៍*(គោលការណ៍)*នេះ គឺមិនមែនដើម្បីបង្កើតជម្លោះរវាងសហគមន៍របស់អ្នក និងក្រុមហ៊ុនចិននោះទេ គឺមានបំណងអោយក្រុមហ៊ុនចិនអនុវត្តតាមច្បាប់ ដូច្នេះពួកគេអាច "**លើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃការវិនិយោគបរទេស និងកិច្ចសហប្រតិបត្តិការ**" ដូចដែលមានចែងនៅចំនុចដំបូងនៃគោលការណ៍ណែនាំនេះ។

នៅពេលដែលអ្នកប្រើប្រាស់គោលការណ៍ណែនាំនេះ សូមអនុញ្ញាតអោយយើងដឹងផង ប្រសិនបើវាមានប្រយោជន៍។ ប្រសិនបើយើងបានឮគំនិតល្អពីអ្នក យើងអាចចែករំលែកគោលការណ៍ណែនាំនេះជាមួយសហគមន៍ដទៃទៀត។ ហើយនៅពេលដែលយើងប្រមូលបានគំនិតយោបល់ និងបទពិសោធន៍នៃការប្រើប្រាស់គោលការណ៍នេះហើយនោះ យើងអាចដាក់គំនិតទាំងនោះនៅក្នុងរបាយការណ៍រួមគ្នាមួយ ហើយដាក់ជូនអាជ្ញាធរចិន ជាមួយនឹងអនុសាសន៍សម្រាប់កែលម្អគោលការណ៍ណែនាំនេះ។

**ទំនាក់ទំនង៖** **អង្គការបណ្តាញការពារទន្លេសេសាន ស្រែពក សេកុង (អង្គការ.ទន្លេបី)**
**អង្គការឃ្លាំមើលទន្លេមេគង្គ**
**ការិ.ទន្លេបី៖** **០៧៥ ៩៧៤ ១១២**

*អង្គការ EarthRights International និង អង្គការ International Rivers បានចូលរួមជួយក្នុងការរៀបចំការណែនាំនេះ ហើយតំណាងសហគមន៍ក៏បានផ្តល់យោបល់នៅក្នុងកថារៀបចំការណែនាំនេះផងដែរ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការជួយរបស់អ្នកទាំងអស់គ្នា។*

*ក្រសួងពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន និងក្រសួងការការពារបរិស្ថាននៃសាធារណរដ្ឋប្រជាមានិតចិន លោក សាង ហេហាន [2013] លេខ ៧៤ ខែកុម្ភៈ 18, 2013 សេចក្តីណែនាំសម្រាប់ការ ការពារបរិស្ថានក្នុងកិច្ចសហប្រតិបត្តិការ និង វិនិយោគ បរទេស៖http://english.mofcom.gov.cn/article/policyrelease/bbb/201303/20130300043226.shtml*

*រាល់សម្រង់នៃការណែនាំក្នុងឯកសារនេះ គឺយោងលើឯកសារភាសាអង់គ្លេស ដែលបានបកប្រែចេញពី ភាសារចិនដែលមាន ក្នុងគេហទំព័រ http://english.mofcom.gov.cn/article/policyrelease/bbb/201303/20130300043226.shtml*